# នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០៣/០៨-១០-២០២១-អ.វ.ត.ក/អ.ជ.ត.ក (០៥)

ភាគីដាក់ឯកសារ៖ មេធាវីការពារក្តីរបស់ មាស មុត

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២៥ ខែតុលា ឆ្នាំ ២០២១

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 01-Nov-21, 11:27
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**ចម្លើយរបស់ មាស មុត តបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីការខកខានរបស់អង្គបុរេជំនុំជម្រះ មិនបានបញ្ជូនរឿងក្តី ០០៣ ទៅជំនុំជម្រះ ដូចដែលបានតម្រូវដោយក្រមខណ្ឌគតិយុត្ត អ.វ.ត.ក.**

---

**ដាក់ដោយ ÷**

**សហមេធាវី ៖**

អាង ឧត្តម

Michael G. KARNAVAS

**ផ្ញើជូន ÷**

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល ៖**

ចៅក្រម គង់ ស្រ៊ីម ប្រធាន

ចៅក្រម C. N. JAYASINGHE

ចៅក្រម សោម សិរីវឌ្ឍ

ចៅក្រម Florence Ndepele MUMBA

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Maureen HARDING CLARK

ចៅក្រម យ៉ា ណារិន

០០៣/០៨-១០-២០២១-អ.វ.ត.ក/អ.ជ.ត.ក (០៥)

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោកស្រី Brenda J. HOLLIS

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងរឿងក្តី ០០៣**

លោក មាស មុត តាមរយៈសហមេធាវីរបស់គាត់ (“មេធាវីការពារក្តី”) តាមរយៈនេះ ឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (“ស.ព.អ.”) អំពីការខកខានរបស់អង្គបុរេជំនុំជម្រះ (“អ.ប.ជ.”) មិនបានបញ្ជូនរឿងក្តី ០០៣ ទៅជំនុំជម្រះ ដូចដែលបានតម្រូវដោយក្របខណ្ឌគតិយុត្ត អ.វ.ត.ក.[1]។ បណ្តឹងសាទុក្ខរបស់ ស.ព.អ. គឺមិនអាចទទួលយកបានទេ។ ស.ព.អ. បង្ខំដោយល្ងង់ខ្លៅ ឱ្យអង្គជំនុំជម្រះតុលាការកំពូល (“អ.ជ.ត.ក.”) ងាកចេញពីសេចក្តីសម្រេចមុនរបស់ពួកគាត់នៅក្នុងរឿងក្តី ០០៤/២ ដោយគ្មានការបង្ហាញសំអាងហេតុសមហេតុផលណាមួយ[2] កំហុសណាមួយនៅក្នុងសំអាងហេតុ ឬ ការផ្លាស់ប្តូរណាមួយនៅក្នុងកាលៈទេសៈទាំងឡាយ ដែលបណ្តាលឱ្យ អ.ជ.ត.ក. សម្រេចលើបញ្ហាផ្លូវច្បាប់ដូចគ្នានៅក្នុងរឿងក្តី ០០៣ ខុសគ្នានោះទេ[3]។ ជាសរុប រាល់ទឡ្ហីករណ៍ទាំងអស់គួរត្រូវបានច្រាន

---

[1] បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអន្តរជាតិអំពីការខកខានរបស់អង្គបុរេជំនុំជម្រះ ក្នុងការបញ្ជូនរឿងក្តី ០០៣ ទៅជំនុំជម្រះ ដូចដែលបានតម្រូវដោយក្របខណ្ឌគតិយុត្ត អ.វ.ត.ក. ចុះថ្ងៃទី ៨ ខែតុលា ឆ្នាំ ២០២១ ឯកសារលេខ ៣ (“បណ្តឹងសាទុក្ខរបស់ ស.ព.អ.”) កថាខណ្ឌ ៤២-៥២។

[2] អ.ជ.ត.ក. គួរអនុវត្តតាមសេចក្តីសម្រេចមុនរបស់ខ្លួន និង គួរតែត្រូវរួចផុតពីការងាកចេញពីសេចក្តីសម្រេចសម្រាប់សំអាងហេតុសមហេតុផលជាប្រយោជន៍យុត្តិធម៌។ *សូមមើល រឿងក្តី នួនជា និង ជនផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ. សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ ២០១១ ឯកសារ E100/6 កថាខណ្ឌ ២៦។ *សូមមើលផងដែរ* សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចស្តីពីភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ឈ្មោះ ជុំ នៅ ចុះថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០១៣ ឯកសារ D11/3/4/2 មតិយោបល់របស់ចៅក្រម Chung និង Downing កថាខណ្ឌ ១៦-១៧។ *រឿងក្តី រដ្ឋអាជ្ញា តទល់ Semanza* សំណុំរឿងលេខ ICTR-97-20-A សេចក្តីសម្រេច ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០០ កថាខណ្ឌ ៩២។

[3] ដោយហេតុថា ស.ព.អ. បានកំពុងស្នើសុំ អ.ជ.ត.ក. ពិចារណាឡើងវិញលើបញ្ហាផ្លូវច្បាប់ ដែលខ្លួនបានសម្រេចនៅក្នុងរឿងក្តី ០០៤/២ ស.ព.អ. ត្រូវបង្ហាញពីកំហុសឱ្យច្បាស់មួយនៅក្នុងសំអាងហេតុរបស់ អ.ជ.ត.ក. ឬ ការផ្លាស់ប្តូរមួយនៅក្នុងកាលៈទេសៈ ដែលតម្រូវឱ្យមានសេចក្តីពិចារណារបស់ អ.ជ.ត.ក.។ *រឿងក្តី នួនជា និង ជនផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ. សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផល សុំឱ្យពិចារណាឡើងវិញនូវសេចក្តីសម្រេចអំពីការស្នើសុំបន្ថែមពេលវេលា និង ចំនួនទំព័រលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ចុះថ្ងៃទី ៧ ខែមិថុនា ឆ្នាំ ២០១៩ ឯកសារ F44/1 ទំព័រ ៤-៥។ *រឿងក្តី នួនជា និង ជនផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ. សេចក្តីសម្រេចលើសារណារបស់សហព្រះរាជអាជ្ញាស្តីពីកិច្ចដំណើរការនីតិវិធីជាមួយនឹងសវនាការលើបណ្តឹងសាទុក្ខ ចុះថ្ងៃទី ៣ ខែធ្នូ ឆ្នាំ ២០១៥ ឯកសារ F30/16/1 ទំព័រ ៤។ *សូមមើលផងដែរ រឿងក្តី រដ្ឋអាជ្ញា តទល់ Šešelj* សំណុំរឿងលេខ IT-03-67-AR72.1 សេចក្តីសម្រេចលើញត្តិសុំឱ្យសេចក្តីពិចារណាលើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍បន្ទាន់បង្ខំពាក់ព័ន្ធនឹងយុត្តាធិការ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០៤ ចុះថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០០៦ កថាខណ្ឌ ៩។

ចោល[4]។

# I. ចម្លើយ

## ក. ដីកាដំណោះស្រាយគឺខុសច្បាប់

១. នៅក្នុងមូលដ្ឋាន ក (កថាខណ្ឌ ៥៣-៦១) ស.ព.អ. អះអាងដោយភាន់ច្រឡំថា សហចៅក្រមស៊ើបអង្កេត ("ស.ច.ស.") ត្រូវបានអនុញ្ញាតឱ្យចេញដីកាដំណោះស្រាយពីរ ពីព្រោះ៖ (ក) ស.ច.ស. មានសិទ្ធិស្មើគ្នា និង ឯករាជ្យ[5] (ខ) វិធាន ៧២ នៃវិធានផ្ទៃក្នុង គឺជាលក្ខណៈបែបឆន្ទានុសិទ្ធិ[6] (គ) ដីកាដំណោះស្រាយទាំងពីរត្រូវបានប្រមើលមើលដោយអ្នកព្រាងទាំងឡាយនៃក្របខណ្ឌ អ.វ.ត.ក. ថា កាលណាមានការមិនស្រុះស្រួលគ្នាដែលមិនអាចផ្សះផ្សាបាន នោះដីកាបញ្ជូនរឿងទៅជំនុំជម្រះគួរត្រូវបញ្ជូនបន្ត ស្របតាមគោលជំហរដើម[7] (ឃ) វិធាន ៦៧ (១) នៃវិធានផ្ទៃក្នុង តម្រូវឱ្យដីកាដំណោះស្រាយមួយត្រូវតែបកស្រាយជាមួយវិធាន ១(២) នៃវិធានផ្ទៃក្នុង ដែលចែងថា ការយោងដល់ ស.ច.ស. រួមទាំងការបំពេញកិច្ចរួមគ្នា និង ការបំពេញកិច្ចជាលក្ខណៈបុគ្គលនីមួយៗ[8] និង (ង) ការប្រៀបធៀបមួយជាមួយនឹងប្រព័ន្ធច្បាប់ស៊ីវិល ដែលដីកាដំណោះស្រាយទាំងពីរមិនត្រូវបានអនុញ្ញាត រំលេចអំពីលក្ខណៈពិសេសនៃក្របខណ្ឌគតិយុត្ត អ.វ.ត.ក. ដែលអនុញ្ញាតឱ្យចេញដីកាដំណោះស្រាយពីរ[9]។

២. ស.ព.អ. មិនបង្ហាញសំអាងហេតុដែលរឹងមាំនិងអាចជឿ មិនបង្ហាញកំហុសនៅក្នុងសំអាងហេតុ ឬ មិនបង្ហាញការផ្លាស់ប្តូរនៅក្នុងកាលៈទេសៈទាំងឡាយ សម្រាប់ឱ្យ អ.ជ.ត.ក. ងាកចេញពីសេចក្តីសម្រេចរបស់ពួកគាត់នៅក្នុងរឿងក្តី ០០៤/២ ទេ[10]។ ស.ព.អ. គ្រាន់តែលើកទឡ្ហីករណ៍ដដែលៗ

---

[4] *សូមមើល រឿងក្តី កាំង ហ្កេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ២០។ *រឿងក្តី រដ្ឋអាជ្ញា តទល់ Stanišić and Simatović* សំណុំរឿងលេខ IT-03-69-A សាលក្រម ចុះថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ២២។

[5] បណ្តឹងសាទុក្ខរបស់ ស.ព.អ. កថាខណ្ឌ ៥៤។

[6] បណ្តឹងសាទុក្ខរបស់ ស.ព.អ. កថាខណ្ឌ ៥៥។

[7] បណ្តឹងសាទុក្ខរបស់ ស.ព.អ. កថាខណ្ឌ ៥៦-៥៧។

[8] បណ្តឹងសាទុក្ខរបស់ ស.ព.អ. កថាខណ្ឌ ៥៨។

[9] បណ្តឹងសាទុក្ខរបស់ ស.ព.អ. កថាខណ្ឌ ៥៩-៦១។

[10] *សូមមើល ខាងលើ*ជើងទំព័រ ១-២។

ដែលមិនបានជោគជ័យនៅចំពោះមុខ អ.ជ.ត.ក. ដោយគ្មានការចង្អុលបង្ហាញណាមួយ ថាហេតុអ្វីទើបការបដិសេធដោយ អ.ជ.ត.ក. ជាកំហុសមួយនោះទេ[11] ។

៣. នៅពេលប្តឹងសាទុក្ខនៅចំពោះមុខ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ ស.ព.អ. បានអះអាងថា វិធាន ៧៧(១៣)(ខ) វិធាន ៧៩(១) និង វិធាន ១(២) នៃវិធានផ្ទៃក្នុង តម្រូវឱ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះត្រូវបញ្ជូនទៅជំនុំជម្រះ ដោយសារដីកានេះមិនត្រូវបានច្រានចោលដោយសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ. និង "នៅតែរស់រវើក"[12]។ អ.ជ.ត.ក. មិនបានរកឃើញកំហុសណាមួយនៅក្នុងសំអាងហេតុរបស់ អ.ប.ជ. ដែលថា ការចេញដីកាដំណោះស្រាយទាំងពីរគឺខុសច្បាប់ និងថាវិធាន ១(២) នៃវិធានផ្ទៃក្នុង មិនបានចែងពីមូលដ្ឋានផ្លូវច្បាប់ ដើម្បីងាកចេញពីលក្ខខណ្ឌតម្រូវនៅក្នុងវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង ក្នុងការចេញដីកាដំណោះស្រាយតែមួយនោះទេ[13]។ អង្គជំនុំជម្រះបានយល់ឃើញយ៉ាងច្បាស់ថា "តើវិធាន១(២) នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យសហចៅក្រមស៊ើបអង្កេតម្នាក់បំពេញកិច្ចជាលក្ខណៈបុគ្គលដែរឬទេ នៅតែត្រូវដោះស្រាយដោយអង្គបុរេជំនុំជម្រះ"[14]។ ប្រសិនបើ អ.ជ.ត.ក. បានកំណត់ថា អ.ប.ជ. បានភាន់ច្រឡំនៅក្នុងការយល់ឃើញថាដីកាដំណោះស្រាយទាំងពីរគឺខុសច្បាប់ នោះអង្គជំនុំជម្រះគួរបានលើកឡើង និង កែតម្រូវកំហុស *តាមគំនិតផ្តួចផ្តើមរបស់ខ្លួន (proprio motua)* ដោយសារការកំណត់ពីបញ្ហានេះជា"មូលដ្ឋានសំខាន់

[11] *សូមមើល រឿងក្តី កាំង ហ្កេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ២០។ *រឿងក្តី រដ្ឋអាជ្ញា តទល់ Stanišić and Simatović* សំណុំរឿងលេខ IT-03-69-A សាលក្រម ចុះថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ២២។

[12] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក បណ្តឹងសាទុក្ខជាបន្ទាន់របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ៤ ខែឧសភា ឆ្នាំ ២០២០ ឯកសារ E004/2/1 កថាខណ្ឌ ៥៥។ *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងលិខិតរបស់ អោ អាន ទាក់ទងនឹងបណ្តឹងសាទុក្ខជាបន្ទាន់របស់គាត់ប្រឆាំងនឹងការរំលត់ជាធរមាននៃសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០២០ ឯកសារ E004/2/1/1/1 កថាខណ្ឌ ៤។

[13] *រឿងក្តី អោ អាន* សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងការបញ្ចប់អានុភាពសំណុំរឿង ០០៤/២ របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១០ ខែសីហា ឆ្នាំ ២០២០ ឯកសារ E004/2/1/1/2 ("សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២") កថាខណ្ឌ ៥២-៥៣។ *រឿងក្តី* អោ អាន សំណុំរឿងលេខ 004/2/07-09-2009- អ.វ.ត.ក/ក.ស.ច.ស (អបជ៦០) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ២០១៩ ឯកសារ D359/24 & D360/33 កថាខណ្ឌ ១២១។

[14] សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៦៨។

សម្រាប់យុត្តិសាស្ត្ររបស់ អ.វ.ត.ក.”[15]។

៤. បន្តបន្ទាប់មក ក្នុងរឿងក្តី ០០៣ និង ០០៤ អ.ប.ជ. បានសម្រេចជាឯកឆន្ទម្តងទៀតថា វិធាន ១(២) នៃវិធានផ្ទៃក្នុង មិនបានផ្តល់មូលដ្ឋានផ្លូវច្បាប់មួយសម្រាប់ឱ្យ ស.ច.ស. ចេញដីកាដំណោះស្រាយពីរទេ[16]។ អ.ប.ជ. មិនបានយល់ឃើញជាឯកឆន្ទថា វិធាន ១(២) នៃវិធានផ្ទៃក្នុង អនុញ្ញាតឱ្យ ស.ច.ស. បំពេញកិច្ចជាលក្ខណៈបុគ្គល ដើម្បីបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ។

៥. សម្រាប់ហេតុផលទាំងនេះ ជាសរុប មូលដ្ឋាន ក គួរត្រូវច្រានចោល។

## ខ. ដីកាដំណោះស្រាយត្រូវចាត់ទុកជាមោឃៈ និង ឥតបានការ

៦. នៅក្នុងមូលដ្ឋាន ខ (កថាខណ្ឌ ៦២-៦៨) ស.ព.អ. អះអាងដោយភាន់ច្រឡំថា ដីកាដំណោះស្រាយមិនមោឃៈ និង ឥតបានការទេ និង ថា អ.ប.ជ. មានភារកិច្ចពិនិត្យលើអង្គសេចក្តីនៃដីកាដំណោះស្រាយ ដែលគាត់អះអាង “សម្រាប់សំអាងហេតុខុសគ្នា បានបញ្ជាក់គាំទ្រដីកាបញ្ជូនរឿងទៅជំនុំជម្រះ”[17]។ ស.ព.អ. អះអាងដោយភាន់ច្រឡំបន្ថែមទៀតថា ប្រសិនបើ អ.ជ.ត.ក. មិនយល់ស្របគ្នា ហើយត្រូវត្រឡប់ទៅពិចារណាលើឧបាស្រ័យរបស់ខ្លួនវិញ នោះ អង្គជំនុំជម្រះត្រូវតែពិចារណាថា តើដីកាដំណោះស្រាយទាំងពីរបាននាំឱ្យមានភាពអយុត្តិធម៌ និង លទ្ធផលអយុត្តិធម៌ធ្ងន់ធ្ងរនៅក្នុងដំណើរការនីតិវិធី “ភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ តម្លៃសង្គមនៃការរារាំងរឿងក្តីមិនឱ្យបន្តទៅមុខ ផលប្រយោជន៍ និង សិទ្ធិរបស់ភាគីទាំងអស់ ហើយនិងភាពសមាមាត្រនៃឧបាស្រ័យណាមួយចំពោះព្យសនកម្មដែលបានចោទប្រកាន់ដែរឬទេ”[18]។

៧. ស.ព.អ. មិនបានបង្ហាញសំអាងហេតុអាចជឿទុកចិត្ត កំហុសនៅក្នុងការផ្តល់សំអាងហេតុ ឬ ការផ្លាស់ប្តូរនៅក្នុងកាលៈទេសៈទាំងឡាយសម្រាប់ឱ្យ អ.ជ.ត.ក. ងាកចេញពីសេចក្តីសម្រេចរបស់

---

[15] *សូមមើល រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ១៥។

[16] សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ៧ ខែមេសា ឆ្នាំ ២០២១ ឯកសារ D266/27 & D267/35 (“សេចក្តីពិចារណារបស់ អ.ប.ជ ក្នុងរឿងក្តី ០០៣”) កថាខណ្ឌ ១០៣-១០៤។ *រឿងក្តី* យឹម ទិត្យ សំណុំរឿងលេខ 004/2/07-09-2009- អ.វ.ត.ក/ក.ស.ច.ស (អបជ៦១) សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ចុះថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ ២០២១ ឯកសារ D381/45 & D382/43 កថាខណ្ឌ ១០៩-១១០។

[17] បណ្តឹងសាទុក្ខរបស់ ស.ព.អ. កថាខណ្ឌ ៦២។

[18] បណ្តឹងសាទុក្ខរបស់ ស.ព.អ. កថាខណ្ឌ ៦៣។

ពួកគាត់នៅក្នុងរឿងក្ដី ០០៤/២ នោះទេ[19]។ "ទទ្បីករណ៍នានារបស់ភាគីមួយដែលគ្មានសក្ដានុពល ដើម្បីច្រានចោល ឬ កែប្រែសេចក្ដីសម្រេច ដែលរងការជំទាស់តវ៉ា អាចត្រូវបានលើកចោលដោយ អង្គជំនុំជម្រះតុលាការកំពូលភ្លាមៗ ហើយមិនចាំបាច់ធ្វើការពិចារណាលើអង្គសេចក្ដីឡើយ" [20]។

៨. អ.ជ.ត.ក. បានសម្រេចនៅក្នុងរឿងក្ដី ០០៤/២ ថា ផលវិបាកនៃការប្រកាសរបស់ អ.ជ.ប.ថា ដីកាដំណោះស្រាយគឺជាលទ្ធផលនៃ*ចំណាត់ការខុសច្បាប់ និង ពុំត្រឹមត្រូវតាមច្បាប់* គឺថា ដីកាដំណោះស្រាយទាំងពីរនេះត្រូវចាត់ទុកជាមោឃៈ និង ឥតបានការ ហើយមតិយោបល់ដាច់ដោយឡែកទៅលើសុពលភាពនៃដីកាដំណោះស្រាយនីមួយៗ គឺ"មិនជាប់ពាក់ព័ន្ធ" "លែងចាំបាច់" និង "ពុំចាំបាច់"ទៀតឡើយ[21]។ អ.ជ.ត.ក. បានពិចារណាថា "កិច្ចដែលមិនសុពល មិនអាចបង្កើតបានផលវិបាក ឬ លទ្ធផលត្រឹមត្រូវតាមច្បាប់ទេ" និង "អាស្រ័យហេតុនេះ វាជាការសមហេតុផលដែលថា ចំណាត់ការប្រភពដើម ដែលជាដីកាដំណោះស្រាយនីមួយៗនោះ ពុំមានអានុភាពផ្លូវច្បាប់ទេ"[22]។ ដោយពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះមួយដែលសុពល ហើយនិងដោយការពិចារណាដែលថា "ពុំមានការយល់ស្របគ្នាបន្ទាប់ពីរយៈពេលដប់បីឆ្នាំនៃការស៊ើបអង្កេត ដែល អោ អាន ស្ថិតក្នុងយុត្តាធិការរបស់តុលាការ" អ.ជ.ត.ក. បានសម្រេចថា "រឿងក្ដី ០០៤/២ ប្រឆាំងនឹងរូបគាត់ គប្បីត្រូវបញ្ចប់នៅចំពោះមុខ អ.វ.ត.ក." [23]។

៩. ស.ព.អ. កំពុងចាក់បញ្ចូលកត្តានានាដែលមិនពាក់ព័ន្ធ សម្រាប់សេចក្ដីពិចារណារបស់ អ.ជ.ត.ក. នៅក្នុងរឿងក្ដី ០០៣ ៖

ក. ដកស្រង់ដោយភាន់ច្រឡំ នូវបទដ្ឋាននៃការពិនិត្យឡើងវិញចំពោះកំហុសនីតិវិធីនៅក្នុងសាលក្រម[24] ដោយមិនអើពើនឹងការយល់ឃើញរបស់ អ.ជ.ប. ដែលថា កំហុស "យ៉ាង

---

[19] *សូមមើល ខាងលើ* ជើងទំព័រ ១-២។

[20] *សូមមើល រឿងក្ដី កាំង ហ្កេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ២០។

[21] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្ដី ០០៤/២ កថាខណ្ឌ ៥៣ កថាខណ្ឌ ៦៧។

[22] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្ដី ០០៤/២ កថាខណ្ឌ ៦៧។

[23] សេចក្ដីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្ដី ០០៤/២ កថាខណ្ឌ ៦៩។

[24] បណ្ដឹងសាទុក្ខរបស់ ស.ព.អ. កថាខណ្ឌ ៣២-៣៣ ដែលដកស្រង់បទដ្ឋាននៃការពិនិត្យបណ្ដឹងសាទុក្ខ នៅក្នុង *រឿងក្ដី នួនជា និង ជនផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ត.ក. សាលដីកា ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ F36 កថាខណ្ឌ ១០០។

ច្បាស់ក្រឡែក” និង “ធ្ងន់ធ្ងរ” របស់ ស.ច.ស. នៅក្នុងការចេញដីកាដំណោះស្រាយទាំងពីរ “បានបង្កផលប៉ះពាល់ដល់ប្រព័ន្ធទាំងមូល ដែលគាំទ្រដោយរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ”[25]។

ខ. អះអាងខុសចំពោះយុត្តិក្រមពីតុលាការសិទ្ធិមនុស្សអឺរ៉ុប ដែលពាក់ព័ន្ធនឹង “ភាពត្រឹមត្រូវនៃនីតិវិធី” និង យុត្តិក្រមរបស់ ស.រ.អ. ដែលពាក់ព័ន្ធនឹងការទប់ស្កាត់ភស្តុតាងដែលខុសច្បាប់ថាជា “យុត្តិសាស្ត្រ” ដែលអាចយកមកអនុវត្តបាននៅ អ.វ.ត.ក.[26]។

គ. នាំឱ្យយល់ខុស នៅក្នុងការស្នើយោបល់ថា ការបញ្ចប់គឺសមស្របតែនៅក្នុងរឿងក្ដីស្ដីពីការប្រព្រឹត្តបែបអមនុស្សធម៌ ឃោរឃៅ និង បន្ទាបបន្ថោក ឬ ធ្វើទារុកម្ម[27] ។ និង

ឃ. នាំឱ្យយល់ខុស នៅក្នុងការអះអាងថា ការស្ទង់មតិមួយអំពីរឿងក្ដីមកពីសាលាក្ដីព្រហ្មទណ្ឌអន្តរជាតិផ្សេងទៀត ដែល *សវនាការ និង ដំណើរការនីតិវិធីបណ្ដឹងឧទ្ធរណ៍* ត្រូវបានបញ្ចប់នៅក្នុងរយៈពេលប្រាំបីឆ្នាំ ទៅ ១៣ ឆ្នាំ ក្រោយពីការបញ្ជូនជនជាប់ចោទទៅសវនាការ បង្ហាញថា រឿងក្ដី ០០៣ ដែលស្ថិតនៅដំណាក់កាលមុនជំនុំជម្រះអស់រយៈពេល ១៣ ឆ្នាំ គឺមិនត្រូវបានពន្យារពេលដែលមិនសមស្របឡើយ[28]។

១០. សម្រាប់ហេតុផលទាំងងនេះ ជាសរុប មូលដ្ឋាន ខ គួរត្រូវច្រានចោល។

## គ. អ.ប.ជ. មិនបានសម្រេចជាឯកឆន្ទតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ

១១. នៅក្នុងមូលដ្ឋាន គ (កថាខណ្ឌ ៦៩-៧៥) ស.ព.អ. អះអាងដោយគ្មានភាពពិតប្រាកដថា អ.ប.ជ.

---

[25] សេចក្ដីពិចារណារបស់ អ.ប.ជ. ក្នុងរឿងក្ដី ០០៣ កថាខណ្ឌ ៨៨ កថាខណ្ឌ ១០៥ កថាខណ្ឌ ១០៨។

[26] បណ្ដឹងសាទុក្ខរបស់ ស.ព.អ. កថាខណ្ឌ ៣៤ ជើងទំព័រ ៥៨ ដែលដកស្រង់ *រឿងក្ដី Ibrahim និង ជនផ្សេងទៀត តទល់ ចក្រភពអង់គ្លេស* សំណុំរឿងលេខ 50541/08, 50571/08, 505373/08, 40351/09 សាលក្រម ចុះថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ ២០១៦ កថាខណ្ឌ ២៥២ និង *រឿងក្ដី Hudson តទល់ Michigan* សំណុំរឿងលេខ ៥៤៧ ស.រ.អ. ៥៨៦, ៥៩១ (ឆ្នាំ ២០០៦)។

[27] បណ្ដឹងសាទុក្ខរបស់ ស.ព.អ. កថាខណ្ឌ ៣៥។

[28] បណ្ដឹងសាទុក្ខរបស់ ស.ព.អ. កថាខណ្ឌ ៦៦ ដែលដកស្រង់ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ មាស មុត សុំឱ្យបញ្ចប់នីតិវិធី បោះត្រា និង ដាក់បញ្ចូលសំណុំរឿង ០០៣ ទៅក្នុងបណ្ណសារ ចុះថ្ងៃទី ៨ ខែកក្កដា ឆ្នាំ ២០២១ ឯកសារ D272/1 កថាខណ្ឌ ១៦។

បានសម្រេចជាឯកឆន្ទតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ[29]។

១២. ស.ព.អ. អះអាងខុសពីសេចក្ដីពិចារណារបស់ អ.ប.ជ. និង សេចក្ដីសម្រេចរួមរបស់ អ.ប.ជ. លើសំណើរបស់ភាគីនានាសុំឱ្យបញ្ចប់ពីដំណើការនីតិវិធីមុនជំនុំជម្រះនៅក្នុងរឿងក្ដី ០០៣។ នៅពេល ស.ព.អ. បានស្នើសុំឱ្យ ស.ច.ស. បញ្ជូនសំណុំរឿង ០០៣ ទៅជំនុំជម្រះ ពួកគាត់បានយល់ឃើញថា ទស្សនៈរបស់ ស.ព.អ. បាន"ផ្អែកលើមតិយោបល់របស់ចៅក្រមអន្តរជាតិនៃ អ.ប.ជ. អំពីអត្ថិភាពនៃការយល់ឃើញជាឯកឆន្ទដែលត្រូវបានចោទប្រកាន់ ដោយចៅក្រមទាំងប្រាំនាក់ថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាព គឺធ្វើឱ្យពាក្យពេចន៍របស់ចៅក្រមជាតិស្ថិតក្រៅបរិបទ ..."[30]។ បន្ទាប់មកទៀត អ.ប.ជ. *មិន*បានបង្គាប់ឱ្យ ស.ច.ស. បញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះទេ ដោយប្រកាសជាឯកឆន្ទថា ខ្លួនមិនអាចសម្រេចបានសំឡេងភាគច្រើនលើសលុបនៅក្នុងសេចក្ដីពិចារណារបស់ខ្លួនលើបញ្ហាចោទសួរ ដែលបានលើកឡើងម្ដងទៀតដោយសំណើរបស់ភាគីនានា (ថាតើត្រូវបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដាក់បញ្ចូលទៅក្នុងបណ្ណសារ)[31]។ ដូចដែល ស.ច.ស. បានយល់ឃើញ "ទស្សនៈណាមួយ ដែលចៅក្រមទាំងប្រាំនាក់បានតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ... នោះត្រូវចាត់ទុកជាបានការ ដោយយោងតាមពាក្យពេចន៍ផ្ទាល់របស់ អ.ប.ជ."[32]។

១៣. សម្រាប់ហេតុផលទាំងនេះ ជាសរុប មូលដ្ឋាន គ គួរត្រូវច្រានចោល[33]។

---

[29] បណ្ដឹងសាទុក្ខរបស់ ស.ព.អ. កថាខណ្ឌ ៦២។

[30] សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបញ្ជូនសំណុំរឿង ០០៣ ទៅអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ២០ ខែសភា ឆ្នាំ ២០២១ ឯកសារ, D270/7 កថាខណ្ឌ ៣០។

[31] សេចក្ដីសម្រេចរួមលើសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និង សហមេធាវីការពារក្ដី មាស មុត ពាក់ព័ន្ធនឹងកិច្ចដំណើការនីតិវិធីក្នុងសំណុំរឿង ០០៣ ចុះថ្ងៃទី ៨ ខែកញ្ញា ឆ្នាំ ២០២១ ឯកសារ D275/1 & D272/3 កថាខណ្ឌ ៧៧។

[32] ដីកាបង្គាប់ឱ្យដាក់សេចក្ដីសន្និដ្ឋានស្ដីពីយុត្តាធិការដែលនៅសេសសល់ ដើម្បីបញ្ចប់សំណុំរឿង ០០៣ ចុះថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ ២០២១ ឯកសារ D273 កថាខណ្ឌ ២។

[33] *សូមមើល រឿងក្ដី កាំង ហ្កេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ២០។ *រឿងក្ដី រដ្ឋអាជ្ញា តទល់ Stanišić and Simatović* សំណុំរឿងលេខ IT-03-69-A សាលក្រម ចុះថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ២២។

### ឃ. រឿងក្តី ០០៣ មិនអាចបញ្ជូនទៅជំនុំជម្រះ ព្រោះគ្មានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលស្មុពល

១៤. នៅក្នុងមូលដ្ឋាន ឃ (កថាខណ្ឌ ៧៦-៨២) ស.ព.អ. អះអាងដោយភាន់ច្រឡំថា បើទោះបី អ.ប.ជ មិនបានសម្រេចជាឯកឆន្ទក្នុការតម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះក្តី ក៏ អ.ប.ជ. មានកាតព្វកិច្ចត្រូវបញ្ជូនរឿងក្តី ០០៣ ទៅជំនុំជម្រះ អនុលោមតាមគោលជំហរដើម ពីព្រោះដីកាបញ្ជូនរឿងទៅជំនុំជម្រះមិនត្រូវបានច្រានចោលដោយសំឡេងភាគច្រើនលើសលុបរបស់ អ.ប.ជ.[34]។

១៥. ស.ព.អ. មិនបង្ហាញសំអាងហេតុដែលអាចជឿទុកចិត្ត មានកំហុសនៅក្នុងការផ្តល់សំអាងហេតុ ឬ មិនបង្ហាញការផ្លាស់ប្តូរនៅក្នុងកាលៈទេសៈទាំងឡាយសម្រាប់ឱ្យ អ.ជ.ត.ក. ងាកចេញពីសេចក្តីសម្រេចរបស់ពួកគាត់នៅក្នុងរឿងក្តី ០០៤/២[35]។ ស.ព.អ. គ្រាន់តែលើកឡើងទឡ្ហីករណ៍ដដែលៗ ដែលមិនបានទទួលជោគជ័យនៅចំពោះមុខ អ.ជ.ត.ក. ដោយគ្មានការចង្អុលបង្ហាញពីហេតុដែលថាការច្រានចោលអំណះអំណាងនិងទឡ្ហីករណ៍របស់ពួកគេដោយ អ.ជ.ត.ក. ជាកំហុសមួយ[36]។

១៦. អ.ជ.ត.ក. បានសម្រេច"យ៉ាងច្បាស់"ថា រឿងក្តីមួយមិនអាចបញ្ជូនទៅជំនុំជម្រះទេ "ក្នុងករណីពុំមានដីកាបញ្ជូនរឿងទៅជំនុំជម្រះដែលស្មុពល" បើទោះបីជាយល់ឃើញថា គោលដៅនៃយន្តការដោះស្រាយការខ្វែងយោបល់គ្នា គឺត្រូវ"ទប់ស្កាត់ភាពទាល់ច្រកមិនឱ្យដំណើរការនីតិវិធីងាកចេញពីការបន្តទៅជំនុំជម្រះ"ក្តី[37]។ អ.ជ.ត.ក. បានយល់ឃើញរួចហើយថា "ទឡ្ហីករណ៍ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ... ថា ក្នុងករណីពុំមានការព្រមព្រៀង និង សំឡេងភាគច្រើនលើសលុប ដើម្បីគាំទ្រដីកាសម្រេចលើកលែងចោទប្រកាន់ទេ នោះគោលជំហរដើមត្រូវយកមកប្រតិបត្តិ ... គេសរសេរ ឬ មិនអើពើពីផលវិបាកនៃការយល់ឃើញ *ជាឯកឆន្ទ* របស់អង្គបុរេជំនុំជម្រះដែលថា ដីកាដំណោះស្រាយ គឺជាលទ្ធផលនៃចំណាត់ការ*ខុសច្បាប់ និង ពុំត្រឹមត្រូវតាមច្បាប់*"[38]។

---

[34] បណ្តឹងសាទុក្ខរបស់ ស.ព.អ. កថាខណ្ឌ ៧៦។

[35] *សូមមើល ខាងលើ* ជើងទំព័រលេខ ១-២ ។

[36] *សូមមើល រឿងក្តី កាំង ហ្កេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សាលដីកា ចុះថ្ងៃទី ៣ ខែកុម្ភៈ ឆ្នាំ ២០១២ ឯកសារ F28 កថាខណ្ឌ ២០។ *រឿងក្តី រដ្ឋអាជ្ញា តទល់ Stanišić and Simatović* សំណុំរឿងលេខ IT-03-69-A សាលក្រម ចុះថ្ងៃទី ៩ ខែធ្នូ ឆ្នាំ ២០១៥ កថាខណ្ឌ ២២។

[37] សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៦៨។

[38] សេចក្តីសម្រេចរបស់ អ.ជ.ត.ក. ក្នុងរឿងក្តី ០០៤/២ កថាខណ្ឌ ៦៧ (ការគូសបញ្ជាក់បន្ថែម)។

១៧.    សម្រាប់ហេតុផលទាំងនេះ ជាសរុប មូលដ្ឋាន ឃ គួរត្រូវច្រានចោល។

## II. សេចក្តីសន្និដ្ឋាន និង សំណើដែលស្នើសុំ

១៨.    ដីកាបញ្ជូនរឿងទៅជំនុំជម្រះនៅក្នុងរឿងក្តី ០០៣ ត្រូវចាត់ទុកជាមោឃៈ និង ឥតបានការ ដូចមតិយោបល់ដាច់ដោយឡែករបស់ចៅក្រមនៃ អ.ប.ជ. ថាមិនពាក់ព័ន្ធ និង លែងចាំបាច់។ ឧបាស្រ័យតែមួយគត់ចំពោះដីកាដំណោះស្រាយដែលខុសច្បាប់ ដែលធានាសិទ្ធិរបស់លោក មាស មុត ក្នុងការទទួលការប្រព្រឹត្តដោយស្មើគ្នា សច្ចភាពផ្លូវច្បាប់ និង ក្នុងការទទួលបានការសម្រេចឆាប់រហ័យ និងជាស្ថាពរនៃរឿងក្តីរបស់គាត់ អនុលោមតាមក្របខណ្ឌ អ.វ.ត.ក. គឺត្រូវបញ្ចប់រឿងក្តី ០០៣ ស្របទៅតាមសេចក្តីសម្រេចរបស់ អ.ជ.ត.ក. នៅក្នុងរឿងក្តី ០០៤/២។

អាស្រ័យហេតុនេះ សម្រាប់ហេតុផលដែលបានជម្រាបជូនខាងលើនេះ **ជាសរុប** អ.ជ.ត.ក. គួរ **ច្រានចោល** បណ្តឹងសាទុក្ខរបស់ ស.ព.អ.។

សូមលោកចៅក្រមទទួលយកសេចក្តីគោរពអំពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២៥** ខែតុលា ឆ្នាំ **២០២១**

**សហមេធាវីការពារក្តីលោក មាស មុត**

អាង ឧត្តម                                        Michael G. KARNAVA